# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០១ ប្រ.ក.ស្ត.ស

## ប្រកាស
## ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៨០១/២៨៩ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាកីឡាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៨០១ /២៩០ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាកីឡាកម្ពុជា
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១ :**

បង្កើតគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា អមទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាសេនាធិការនៃក្រុមប្រឹក្សាកីឡាកម្ពុជា ។

**ប្រការ ២ :**

គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាកីឡាកម្ពុជា ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការដឹកនាំផ្ទាល់របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសហាធិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកីឡាកម្ពុជា។

ICPL01

ប្រការ ៣ :

ភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា មានដូចតទៅ ÷

- សិក្សាស្រាវជ្រាវនូវរាល់វិធី ដើម្បីអភិវឌ្ឍវិស័យកីឡា ក្នុងព្រះរាជាណាចក្រកម្ពុជា
- លើកទស្សនៈកសាងផែនការ និងកម្មវិធី ដើម្បីអភិវឌ្ឍកីឡាកម្ពុជា រួចដាក់ជូនក្រុមប្រឹក្សាកីឡាកម្ពុជា ពិនិត្យ និងសម្រេច
- អនុវត្តរាល់ការងារ ដែលក្រុមប្រឹក្សាកីឡាកម្ពុជាដាក់ចុះ មានជាអាទិ៍ ការងារសម្រប សម្រួល ណែនាំ ជំរុញ ជួយឧបត្ថម្ភ និងលើកស្ទួយវិស័យកីឡា
- សហការជាមួយក្រសួងអប់រំយុវជន និងកីឡាដើម្បីសម្រេចភារកិច្ចរបស់ខ្លួន
- សហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងគណៈកម្មាធិការប៉ារ៉ាឡាំពិក កម្ពុជា សហព័ន្ធកីឡាជាតិ និងសម្ព័ន្ធសហគមកីឡាខេត្ត ក្រុង អង្គភាព ដើម្បីជំរុញ ការអភិវឌ្ឍវិស័យកីឡា និងការចូលរួមប្រកួតលើឆាកអន្តរជាតិ
- ចុះធ្វើការត្រួតពិនិត្យការងារអនុវត្តផែនការ និងកម្មវិធីដែលក្រុមប្រឹក្សាកីឡាកម្ពុជាដាក់ចុះ។

ប្រការ ៤ :

គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា មានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១. | ឯកឧត្តម សេង លឹមនៅ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | លោក មាស សារិន តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. | ឯកឧត្តម ឡេង ប៉េងឡុង សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៤. | លោក ខឹម ឌិសិទ្ធ ប្រធាននាយកដ្ឋានអប់រំ សុខាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ |
| ៥. | លោក ប្ញូន លឹមហេង ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧. | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៨. | តំណាងគណៈកម្មាធិការជាតិអូឡាំពិក | សមាជិក |
| ៩. | តំណាងគណៈកម្មាធិការប៉ារ៉ាឡាំពិក | សមាជិក |
| ១០. | តំណាងសហព័ន្ធកីឡាឯកត្តជន | សមាជិក |
| ១១. | តំណាងសហព័ន្ធកីឡាសមូហភាព | សមាជិក |

អ្នកតំណាងដែលជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវបានចាត់តាំងដោយអង្គភាពដើមរបស់ខ្លួន និងបញ្ជូនមកគណៈកម្មាធិការប្រតិបត្តិ ។ សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវអញ្ជើញចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន។

ICPL01

ប្រការ ៥ :

នាយកដ្ឋានអប់រំ សុខាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍មាន :

១.ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច

២.ផ្នែកកីឡាឯកត្តជន

៣.ផ្នែកកីឡាសមូហភាព

សមាសភាពផ្នែកទាំង ៣ នេះ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា ។

ប្រការ ៦ :

បណ្តានាយកដ្ឋានរបស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលមានការពាក់ព័ន្ធ ត្រូវចូលរួមសហការជាមួយគណៈកម្មាធិការប្រតិបត្តិទៅតាមជំនាញរៀងៗខ្លួន ។

គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា ប្រើប្រាស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីដំណើរការការងាររបស់ខ្លួន ព្រមទាំងអាចទទួល និងប្រើប្រាស់ជំនួយឧបត្ថម្ភដែលគណៈកម្មាធិការបានទទួលពីសប្បុរសជនជាតិ និងអន្តរជាតិ ។

ប្រការ ៧ :

ដើម្បីអនុវត្តការងាររបស់ខ្លួនគណៈកម្មាធិការប្រតបត្តិ នៃក្រុមប្រឹក្សាកីឡាកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៨ :

បណ្តាអង្គភាព នាយកដ្ឋាននៃទីស្តីការគណៈរដ្ឋមន្ត្រី សាមីអង្គភាព និងសាមីខ្លួនដូចមានចែងក្នុងប្រការ ៤ និងប្រការ ៥ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៧ ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី

សុខ អាន

ចម្លងជូនៈ

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សមាជិកក្រុមប្រឹក្សាកីឡាកម្ពុជា

រាជកិច្ច

- ដូចប្រការ ៤ និងប្រការ ៥
- ឯកសារ.កាលប្បវត្តិ